ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២០-៩-២០១២ -ព្រះរាជក្រម នស/រកម/០៩១២/០០៨ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋកាតា ស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា ៧០៩៣


### ២~ព្រះរាជក្រឹត្យ


១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨១៥ ស្តីពី ការលុបឈ្មោះមន្ត្រីរាជការចំនួន ០១ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយមូលហេតុមរណភាព ៧១០៧

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨១៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៧១០៨

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨១៧ ស្តីពី ការលុបឈ្មោះ ឧត្តមសេនីយ៍ទោ **ច័ន្ទ ទិត្យឌី** ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ៧១០៩

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨១៨ ស្តីពី ការលុបឈ្មោះ នាយទាហាន ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៧១១០

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨១៩ ស្តីពី ការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី **ពេជ្រ សុទ្ធិដា** នាយនគរបាលជាតិជាន់ខ្ពស់ ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ មាន ឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ៧១១១

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២០ ស្តីពី ការដាក់ឯកឧត្តម **ជា សុផារ៉ា** ឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាមុខតំណែងនយោបាយ នៅដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ៧១១២

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២១ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ១៩ រូប ៧១១៣

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២២ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **យឹម សំណាង** នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧១១៥

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សមាជិកក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ នៃលេខាធិការដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ចំនួន ១០ រូប ៧១១៦

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ១៤ រូប ៧១១៧

១៣-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន ចំនួន ៤៧ រូប ៧១១៨

១៤-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៧ ស្តីពី ការតែងតាំងព្រះគ្រូ **នៅ យី** ប្រធានពុទ្ធមណ្ឌលវិបស្សនាធុរៈកម្ពុជា ឱ្យឡើងទីជា ព្រះធម្មវិបស្សនា ព្រះរាជាគណៈថ្នាក់ចត្វា គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ៧១២១

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៨ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះ សពឯកឧត្តម **ចាន់ តិន** នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ៧១២២

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣០ ស្តីពី ការលុបឈ្មោះចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ចំពោះឧត្តមសេនីយ៍ត្រី **ឈូច ចំណាន** ៧១២៣

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លាង ខេនស៊ុង** (LEONG KHEN TSHUNG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតនៅខេត្តសាបា ប្រទេសម៉ាឡេស៊ី ៧១២៤

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ៊ូ អែនតូនី តេងជុង** (HU ANTHONY TENGJUN) ជនជាតិចិន សញ្ជាតិបារាំង កើតនៅទីខេត្តស៊ីជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ហ៊ូ អែនតូនី** (HU ANTHONY ) ៧១២៥

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **អ៊ុំមី គូលស៊ុំ ម៉ែនណាន** (UMME KULSUM MANNAN) ជនជាតិបង់ក្លាដែស សញ្ជាតិបង់ក្លាដែស កើតនៅទីក្រុងជីតាហ្គុង ប្រទេសបង់ក្លាដែស ៧១២៦

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនឯកឧត្តម **ជា ចាន់តុំ** ពីឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងផែនការ ៧១២៧

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៥ ស្ដីពី ការតែងតាំងសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្ដេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយ នៃ ព្រះ រាជាណាចក្រកម្ពុជា ជា កិត្តិឧទ្ទេសបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ៧១២៨

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៦ ស្ដីពី ការតែងតាំងសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកៈនិកាយ នៃ ព្រះរាជាណាចក្រកម្ពុជា ជា កិត្តិឧទ្ទេសបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ៧១២៩

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៧ ស្ដីពី ការតែងតាំងសម្ដេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្ដេចព្រះមហាសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ ជា កិត្តិឧទ្ទេសបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ៧១៣០


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២១-៩-២០១២ -អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្ដីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើអចិន្ត្រៃយ៍ឆ្នាំ ២០០២ នូវផ្ទៃដីសរុបចំនួន ១.៧២១ ហិកតា នៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង និង ធ្វើអនុបយោគមកជាដី ឯកជនរបស់រដ្ឋ និង ការ ធ្វើប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្ដែង ៧១៣១

២១-៩-២០១២ -អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៧១៣៤

*-អនុក្រឹត្យលេខ ១៥៥ អនក្រ.បក មិនទាន់បានទទួល*

២៥-៩-២០១២ -អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្ដីពី ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១៣ ៧១៣៦

២០-៩-២០១២ -អនុក្រឹត្យលេខ ១២០១ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ៧១៣៩

២១-៩-២០១២ -អនុក្រឹត្យលេខ ១២០២ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៧១៤១

២១-៩-២០១២ -អនុក្រឹត្យលេខ ១២០៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧១៤៣

២៥-៩-២០១២ -អនុក្រឹត្យលេខ ១២០៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ ៧១៤៤


## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


៣១-៨-២០១២ -ប្រកាសលេខ ៨៩០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡើម ថយ អ៊ិនធើណេសិនណល បង្កើតរោងចក្រ ផលិតតុក្កតាគ្រប់ប្រភេទ ៧១៤៥

៣១-៨-២០១២ -ប្រកាសលេខ ៨៩១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉កម៉ាស (ខេមបូឌា) ហ្គាមេន អិមអេហ្វជី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧១៤៩

៣១-៨-២០១២ -ប្រកាសលេខ ៨៩២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេច & យីន បេសវេ ហ្វេសិន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧១៥៣

៣១-៨-២០១២ -ប្រកាសលេខ ៨៩៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេ ធី អេច ថេកស្ទាយ (ខេមបូឌា) អ៊ីន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧១៥៧

៣១-៨-២០១២ -ប្រកាសលេខ ៨៩៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុង ជី ខេមបូ អ៊ិនធើណេសិនណល បង្កើតរោងចក្រ ផលិតថង់ប្លាស្ទិក, បន្ទះប្លាស្ទិក ៧១៦១

៣១-៨-២០១២ -ប្រកាសលេខ ៨៩៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូនីស អ៊ែតធីវវែរ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧១៦៥

៣១-៨-២០១២ -ប្រកាសលេខ ៨៩៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាយ យ៉ាំង (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧១៦៩

៣១-៨-២០១២ -ប្រកាសលេខ ៨៩៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្លែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) បង្កើតរោងចក្រ ផលិតឧបករណ៍ស្តាប់សម្លេងភ្ជាប់ត្រចៀក, ឧបករណ៍សាកភ្លើង, តុក្កតា ៧១៧៣

០៥-៩-២០១២ -ប្រកាសលេខ ៩០១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គ្លូរី នីតវែរ អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ចាក់ ៧១៧៧


## ២_ឯកសារគ្រសួងពាណិជ្ជកម្ម


២៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៧៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីស៊ីអេស វិល្ល ខូ អិលធីឌី** ៧១៨១

២៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៧៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខិសាល មានរិទ្ធ ឌីវេឡុបមេន (ឌី អិម អ ឌី)** ៧១៨៣

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨០៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វអេវើ លីឌីង ប្រូភឺធី (ខេមបូឌា) លីមីធីត** ៧១៨៥

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ាំង ស៊ា ស៊ីុង យិ (ខេមបូឌា) ហូលឌីង លីមីធីត** ៧១៨៧

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨០៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.អាយ.ជី** ៧១៨៩

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨០៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សម្បត្តិ ផ្លេធីណើម** ៧១៩១

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨១០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **អ៊ិមអធី-ធីស៊ីស៊ី ខិនិយោគទុន ស្គរអំពៅ** ៧១៩៣

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨១៣ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការសុំបង្កើត សាខារបស់ក្រុមហ៊ុន **អ៊ីហ្សីខម ខូ អិលធីឌី "ខេត្តព្រះសីហនុ"** ៧១៩៥

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨១៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការសុំបង្កើត សាខារបស់ក្រុមហ៊ុន **ដីប្រ៉ែហ្វខឌីតែនី ទីឡា (ខេមបូឌា) " ប្រ៉ែហ្វខឌីតែនី ហ្វាញ អាគ ហ្វូថេល** ៧១៩៦

២៧-៥-២០១១ -លិខិតបញ្ជាក់លេខ ២៨១៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តៃយ៉ុខ គ្រុប** ៧១៩៧

# ព្រះរាជក្រម

នស/រកម/០៩១២/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា ស្តីពី ការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋកាតា ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា ដែលបានចុះហត្ថលេខានៅទីក្រុងដូហា នាថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តពល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម/០៩១២/០៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ហត្ថលេខា

វង សូត

លេខ: ៧០៧ ច.ល

ដើម្បីថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា
# ស្តីពីការគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា
ក្នុងគោលបំណងពង្រឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរ
នៅក្នុងការស្វែងរកការគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មកម្ពុជានៅរដ្ឋកាតា
បានព្រមព្រៀងដូចតទៅ:

## មាត្រា (១)

ក្រសួងការងារនៃរដ្ឋកាតា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំឱ្យមានវិធាន និងបទបញ្ជាជាចាំបាច់ សម្រាប់អនុវត្តបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា (២)

ការជ្រើសរើសហត្ថពលកម្មពីព្រះរាជាណាចក្រកម្ពុជា និងការចូលទៅ និងការប្រើប្រាស់ហត្ថពលកម្មនៅក្នុងរដ្ឋកាតា ត្រូវគ្រប់គ្រងដោយច្បាប់ និងនីតិវិធីដែលកំពុងអនុវត្តនៅក្នុងប្រទេសទាំងពីរ ។

## មាត្រា (៣)

១-ក្រសួងការងារនៃរដ្ឋកាតា ត្រូវជម្រាបមកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា អំពីសំណើជ្រើសរើសរបស់និយោជកនានានៅក្នុងរដ្ឋកាតា ដែលស្នើសុំប្រើប្រាស់ហត្ថពលកម្មកម្ពុជា ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ចែងសម្រេចតាមការស្នើសុំនេះ ស្របទៅតាមមធ្យោបាយ និងធនធានដែលខ្លួនមាន។

២-បើនិយោជកនៅរដ្ឋកាតាមានបំណងជ្រើសរើស និងប្រើប្រាស់ហត្ថពលកម្ម ដែលមានគុណវុឌ្ឍិជាពិសេស និយោជកនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគុណវុឌ្ឍិ នៅក្នុងសំណើរបស់ខ្លួន ដែលបញ្ជូនទៅក្រសួងការងារនៃរដ្ឋកាតា។

៣-និយោជកកាតា ត្រូវបានអនុញ្ញាឱ្យតាមមើល និងបំពេញឱ្យបានគ្រប់គ្រាន់នូវនីតិវិធីទាំងអស់ ដែលបានកំណត់សម្រាប់ការជ្រើសរើសកម្មករ និងការធ្វើដំណើររបស់កម្មករពីប្រទេសកម្ពុជាទៅប្រទេសកាតា។ ការបំពេញនេះនិយោជកអាចធ្វើដោយខ្លួនឯង ឬដោយអ្នកតំណាង ដែលបានអនុញ្ញាតក្នុងចំណោមបុគ្គលិករបស់ខ្លួន ឬដោយការិយាល័យជ្រើសរើស ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ។

## មាត្រា (៤)

ពាក្យស្នើសុំជ្រើសរើសត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគុណវុឌ្ឍិ បទពិសោធន៍ និងឯកទេស ដែលត្រូវការ រយៈពេលកិច្ចសន្យា លក្ខខណ្ឌការងារលម្អិត ជាពិសេសប្រាក់ឈ្នួល ប្រាក់វិភាជសម្រាប់ការបញ្ចប់ការងារ រយៈពេលសាកល្បងការងារ និងបរិក្ខានានាផ្សេងទៀតទាក់ទងទៅដល់ការដឹកជញ្ជូន និងការស្នាក់នៅ ក៏ដូចជាព័ត៌មានជាមូលដ្ឋាននានា ដែលអាចធ្វើឱ្យកម្មករធ្វើសេចក្តីសម្រេចចិត្តក្នុងការចុះហត្ថលេខាលើកិច្ចសន្យាការងារ។

## មាត្រា (៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់វិធានការណ៍ សម្រួលដល់នីតិវិធីនៃការពិនិត្យសុខភាព ការទទួលបានលិខិតឆ្លងដែន និងការអនុញ្ញាតឱ្យកម្មករ ដែលមានបំណងទៅធ្វើការនៅរដ្ឋកាតា អាចធ្វើដំណើរបាន និងត្រូវផ្តល់ដល់កម្មករនូវព័ត៌មានស្តីពីលក្ខខណ្ឌការងារ ការចំណាយផ្សេងៗ និងបទដ្ឋាននៃការរស់នៅនៅក្នុងរដ្ឋកាតា។

## មាត្រា (៦)

រដ្ឋាភិបាលនៃរដ្ឋកាតា អាចនឹងចាត់ចែងតាមនីតិវិធី ធ្វើមាតុភូមិនិវត្តកម្មករកម្ពុជាមួយចំនួន ដែលផុតសុពលភាពនៃកិច្ចសន្យាការងារ។ រដ្ឋាភិបាលនេះអាចនឹងចាត់ចែងតាមនីតិវិធីដូចគ្នានេះផងដែរ នៅមុនពេលផុតសុពលភាពនៃកិច្ចសន្យាការងារ នៅក្នុងករណីដែលតម្រូវការនៃការប្រើប្រាស់កម្មករត្រូវបានបញ្ចប់។ ក្នុងករណីចុងក្រោយនេះ ប្រាក់ឈ្នួលរបស់កម្មករ និងសិទ្ធិផ្សេងៗដែលបានកំណត់ក្នុងកិច្ចសន្យាការងារនឹងត្រូវផ្តល់ជូនពួកគេ ឬត្រូវផ្តល់ជូនពួកគេឱ្យបានត្រឹមត្រូវតាមច្បាប់របស់រដ្ឋកាតា។

## មាត្រា (៧)

រដ្ឋាភិបាលនៃរដ្ឋកាតាអាចនឹងចាត់ចែងតាមនីតិវិធី ដើម្បីធ្វើមាតុភូមិនិវត្តកម្មករកម្ពុជាមួយចំនួន នៅពេលដែលវត្តមានរបស់ពួកគេប្រែទៅជាផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ និងសន្តិសុខជាតិរដ្ឋកាតា។ ករណីនេះមិនត្រូវធ្វើឱ្យបាត់បង់ផលប្រយោជន៍ទាំងឡាយ ដែលត្រូវបានកំណត់ផ្តល់ឱ្យកម្មករ ដោយកិច្ចសន្យាការងារ និងដោយច្បាប់ការងារនៃរដ្ឋកាតាឡើយ។

## មាត្រា (៨)

ក-និយោជកត្រូវរ៉ាប់រងសោហ៊ុយទាំងអស់សម្រាប់កម្មករធ្វើដំណើរពីព្រះរាជាណាចក្រកម្ពុជា ទៅដល់កន្លែងធ្វើការងារនៅរដ្ឋកាតា នៅពេលកម្មករចូលទៅធ្វើការជាលើកដំបូង ហើយត្រូវរ៉ាប់រងរាល់ចំណាយសម្រាប់កម្មករធ្វើដំណើរពីរដ្ឋកាតា មកព្រះរាជាណាចក្រកម្ពុជាវិញ នៅពេលដែលកម្មករបានបញ្ចប់កិច្ចសន្យាការងារ។ និយោជកក៏ត្រូវរ៉ាប់រងចំណាយផងដែរ សម្រាប់ការធ្វើដំណើរទៅ និងមក ក្នុងពេលឈប់សម្រាកនៅព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយកិច្ចសន្យាការងារ។ ចំណាយទាំងអស់នេះ មិនត្រូវរាប់បញ្ចូលតម្លៃធ្វើលិខិតឆ្លងដែន និងប្រាក់កក់ណាមួយនោះឡើយ។

ខ-និយោជកមិនផ្តល់ប្រាក់ឱ្យកម្មករ សម្រាប់ការចំណាយត្រឡប់មកមាតុភូមិវិញទេ ក្នុងករណីទាំងពីរខាងក្រោម:

១-បើកម្មករលាឈប់ពីការងារមុនពេលចប់កិច្ចសន្យា។

២-បើកម្មករមានកំហុសធ្ងន់ ដែលតម្រូវឱ្យបញ្ឈប់ពីការងារ ដោយមិនចាំបាច់មានការជូនដំណឹង និងមិនចាំបាច់មានការផ្តល់ប្រាក់វិភាជន៍បញ្ចប់ការងារ ស្របទៅតាមច្បាប់ស្តីពីការងារនៃរដ្ឋកាតា។

## មាត្រា (៩)

១-លក្ខខណ្ឌការងារសម្រាប់កម្មករកម្ពុជានៅរដ្ឋកាតា ត្រូវកំណត់ដោយកិច្ចសន្យាការងារជាបុគ្គល រវាងកម្មករនិងនិយោជក ស្របតាមកិច្ចសន្យាគំរូ ដែលភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះ។ កិច្ចសន្យាការងារ ត្រូវកំណត់អំពីលក្ខខណ្ឌការងារជាមូលដ្ឋាន ដែលស្តីពីភារកិច្ច និង សិទ្ធិ ស្របទៅតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ និងច្បាប់ស្តីពីការងារនៃរដ្ឋកាតា។

២-កិច្ចសន្យាការងារ ត្រូវធ្វើឡើងជាភាសាអារ៉ាប់ និងភាសាអង់គ្លេស ជាបីច្បាប់ ដែលត្រូវរក្សាទុកដោយនិយោជកមួយច្បាប់ កម្មករមួយច្បាប់ និងរក្សាទុកនៅក្រសួងការងារនៃរដ្ឋកាតាមួយច្បាប់។

## មាត្រា (១០)

កិច្ចសន្យាការងារជាបុគ្គល ត្រូវតែកំណត់អំពីកាតព្វកិច្ចរបស់និយោជក ដែលទាក់ទងទៅនឹងការស្នាក់នៅរបស់កម្មករ និងប្រភេទនៃការស្នាក់នៅ ឬការបើកប្រាក់វិភាជន៍សម្រាប់ការស្នាក់នៅ និងសម្រាប់ការព្យាបាលរបស់កម្មករ។

## មាត្រា (១១)

អត្ថបទជាភាសាអារ៉ាប់នៃកិច្ចសន្យាការងារ គឺជាភាសាមួយ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងការងារ និងតុលាការនៃរដ្ឋកាតា។ និយោជកមិនអាចស្នើសុំធ្វើការផ្លាស់ប្តូរបទប្បញ្ញត្តិណាមួយនៃកិច្ចសន្យាការងារបានឡើយ លើកលែងតែការផ្លាស់ប្តូរនោះផ្តល់ផលប្រយោជន៍ដល់កម្មករ ហើយត្រូវមានការពិនិត្យយល់ព្រមដោយក្រសួងការងារនៃរដ្ឋកាតា។

## មាត្រា (១២)

កិច្ចសន្យាការងារដែលបានធ្វើឡើងនៅរដ្ឋកាតា ត្រូវតែអនុម័តដោយក្រសួងការងារនៃរដ្ឋកាតា និងស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជានៅក្រុងដូហា។ កិច្ចសន្យាការងារដែលធ្វើឡើងនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុម័តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងស្ថានទូត ឬស្ថានកុងស៊ុលនៃរដ្ឋកាតានៅព្រះរាជាណាចក្រកម្ពុជា។

## មាត្រា (១៣)

១-អាជ្ញាធរមានសមត្ថកិច្ចនៃក្រសួងការងារនៃរដ្ឋកាតា ត្រូវតាមឃ្លាំមើលការអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២-ក្នុងករណីដែលកើតមានវិវាទរវាងនិយោជក និងកម្មករ ក្នុងការអនុវត្តកិច្ចសន្យាការងារ ពាក្យបណ្តឹងត្រូវធ្វើទៅក្រសួងការងារនៃរដ្ឋកាតា ដើម្បីដោះស្រាយដោយមិត្តភាព។ បើមិនអាចដោះស្រាយដោយមិត្តភាពបានទេ វិវាទនោះត្រូវតែបញ្ជូនទៅអាជ្ញាធរយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងរដ្ឋកាតា។

## មាត្រា (១៤)

កិច្ចសន្យាការងារត្រូវតែបញ្ចប់តាមកាលបរិច្ឆេទ ដែលបានកំណត់រួចហើយ ដោយមិនចាំបាច់ជូនដំណឹងជាមុនឡើយ។ បើនិយោជកមានបំណងបន្តកិច្ចសន្យា និយោជកត្រូវជូនដំណឹងជាលាយលក្ខអក្សរដល់កម្មករអំពីបំណងបន្តកិច្ចសន្យាក្នុងរយៈពេលយ៉ាងតិចសាមសិប (៣០)ថ្ងៃ មុនថ្ងៃចប់កិច្ចសន្យា។

## មាត្រា (១៥)

កម្មករត្រូវបានអនុញ្ញាតឱ្យផ្ទេរមកប្រទេសកម្ពុជា នូវប្រាក់សន្សំដែលបានមកពីប្រាក់ឈ្នួល ស្របទៅតាមបទបញ្ជាខាងហិរញ្ញវត្ថុនៃរដ្ឋកាតា ។

## មាត្រា (១៦)

ភាគីទាំងពីរត្រូវបង្កើតគណៈកម្មការរួមមួយ ដែលរួមមានសមាជិកមកពីភាគីម្ខាងៗ ចំនួនមិនលើសពីប្រាំ (៥)នាក់ ។ គណៈកម្មការរួមនេះមានភារកិច្ចដូចតទៅៈ

១-សម្របសម្រួលរវាងរដ្ឋាភិបាលទាំងពីរ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ និងចាត់វិធានការណ៍ជាចាំបាច់នៅក្នុងការងារនេះ ។

២-បកស្រាយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ក្នុងករណីដែលកើតមានវិវាទ ដែលជាប់ទាក់ទង និងដោះស្រាយរាល់ការលំបាកទាំងឡាយដែលកើតឡើងនៅក្នុងការអនុវត្ត ។

៣-ពិនិត្យមើលឡើងវិញឱកាសការងារនៅរដ្ឋកាតា ដែលរួមមានព័ត៌មានស្តីពីផែនការនានានៅរដ្ឋកាតា សក្តានុពលនៃឱកាសការងារក្រោមផែនការទាំងនោះ ប្រភេទ និង ចំណាត់ថ្នាក់នានានៃការងារ និងមុខជំនាញដែលត្រូវការ និងបំណងប្រាថ្នារបស់ពលរដ្ឋខ្មែរក្នុងការប្រើប្រាស់ឱកាសទាំងនោះ ។

៤-លើកសំណើសម្រាប់ការពិនិត្យ និងកែសម្រួលបទប្បញ្ញត្តិទាំងអស់ ឬមួយចំនួននៃកិច្ចព្រមព្រៀងនេះទៅតាមការចាំបាច់ ។

គណៈកម្មការរួមនេះត្រូវជួបប្រជុំដោយប្តូរវេនក្នុងមួយឆ្នាំម្តង នៅក្នុងប្រទេសទាំងពីរ ។ បើមានការចាំបាច់ គណៈកម្មការរួមនេះក៏ត្រូវជួបប្រជុំគ្នាផងដែរ ។

## មាត្រា (១៧)

ការធ្វើវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងដោយការព្រមព្រៀងគ្នារវាងរដ្ឋាភិបាលទាំងពីរ ហើយបន្ទាប់មកត្រូវអនុវត្តទៅតាមនីតិវិធីច្បាប់ដូចគ្នានៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា (១៨)

ភាគីទាំងពីរ ដែលបានព្រមព្រៀងគ្នា ត្រូវស្នើសុំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ ហើយកិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរឯកសារផ្តល់សច្ចាប័នរួចហើយ ។ កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈពេលបី (៣)ឆ្នាំ ហើយអាចពន្យាសុពលភាពដែលមានរយៈពេលដូចគ្នា លើកលែងតែភាគីណាមួយក្នុងចំណោមភាគីទាំងពីរ ទាមទារឱ្យបញ្ចប់ជាលាយលក្ខអក្សរ ប្រាំមួយ (៦)ខែមុនពេលអស់សុពលភាព ។

ដើម្បីជាសក្ខីភាព ភាគីនីមួយៗដែលទទួលបានសិទ្ធិប្រទាន បានចុះហត្ថលេខានៅខាងក្រោម ។

ធ្វើនៅទីក្រុងដូហា នៅ 6/6/1432.A.H. ត្រូវនឹងថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ ជាភាសា អារ៉ាប់ ភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទនីមួយៗមានតម្លៃស្មើគ្នា ហើយក្នុងករណីមានការបកស្រាយផ្ទុយគ្នាណាមួយ ភាសាអង់គ្លេសត្រូវបានយកមកធ្វើជាមូលដ្ឋានក្នុងការបកស្រាយ ។

**សម្រាប់ព្រះរាជាណាចក្រកម្ពុជា**

**ចម សុត**

**សម្រាប់រដ្ឋកាតា**

**Nasser Bin Abdullah AL Hamidi**

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

# AGREEMENT BETWEEN THE GOVERNMENT OF THE STATE OF QATAR AND THE GOVERNMENT OF THE KINGDOM OF CAMBODIA CONCERNING THE REGULATION OF MANPOWER EMPLOYMENT IN THE STATE OF QATAR

The Government of the State of Qatar and the Royal Government of Cambodia;

Desirous of strengthening the ties of friendship between them;

Seeking to regulate the employment of Cambodian Manpower in the State of Qatar;

Have agreed as follows:

## Article ( 1 )

The Ministry of Labour in the State of Qatar and the Ministry of ***Labour and Vocational Training*** in the Kingdom of Cambodia shall lay down the necessary rules and regulations for the implementation of the provisions of this Agreement.

## Article ( 2 )

Recruitment of manpower from ***the Kingdom of*** Cambodia and its entry and employment in the State of Qatar shall be regulated in accordance with the relevant laws and procedures applied in the two countries.

## Article ( 3 )

1- The Ministry of Labour in the State of Qatar shall present Ministry of ***Labour and Vocational Training*** in the Kingdom of Cambodia the recruitment applications from employers in the State of Qatar for the employment of Cambodian manpower. Ministry ***of Labour and Vocational Training*** in the Kingdom of Cambodia shall endeavor to meet such applications within means and resources available to it.

2- If an employer in the State of Qatar wishes to recruit and employ manpower with special qualifications, he shall specify such qualifications in his application to the Ministry of Labour in the State of Qatar.

3- The Qatari employer, either himself or by authorizing a representative from among his staff or through a recruitment office authorized by the Ministry of Labour, is permitted to follow up and complete all the procedures required for the selection of workers and their travel from ***the Kingdom of*** Cambodia to the State of Qatar.

## Article ( 4 )

Recruitment applications shall state the required qualifications, experience and specialization, the probable duration of contract, detailed conditions of employment, especially the wages, end of service gratuity, probationary period and facilities regarding transport and accommodation as well as all basic information that may enable the workers to decide on signing the employment contract.

## Article ( 5 )

The Ministry ***of Labour and Vocational Training*** in the Kingdom of Cambodia shall take the necessary measures to facilitate the medical examination procedure, obtaining passports and permission to travel for the workers desiring to work in the State of Qatar as well as provide such workers with information on working conditions, expenses and living standards in Qatar.

## Article ( 6 )

The Government of the State of Qatar may take procedures to repatriate any number of Cambodian workers on the expiry of their contracts of employment. It may also take the same procedures before the expiry of the duration of the

contracts when the needs for the employment comes to an end, provided that in this latter case the wages of the workers and other rights accruing to them under the contracts of employment concluded with them or under the Labour Law of the State of Qatar be paid to them.

### Article ( 7 )

The Government of the State of Qatar may take procedures to repatriate any number of Cambodian workers if their presence in the State of Qatar becomes contrary to the public interest or the national security of the State. This shall be without prejudice to the rights accruing to the labour under the contracts of employment or the Labour Law of the State of Qatar.

### Article ( 8 )

A- The employer shall bear all travel expenses of workers from the Kingdom of Cambodia to the work site in the State of Qatar when they first join work and shall also bear their travel expenses from Qatar at the end of their employment contract. The employer shall also bear the workers' two-way travel expenses during the leave period under the work contract. Such expenses shall not include the cost of passport issuance and payment of any deposits.

B- The employer shall not pay the expenses of the worker for returning home in the following two cases:

1. If the worker resigns before the end of the employment contract.
2. If the worker commits a fault that necessitates his/her dismissal from work without warning and without payment of the end of service gratuity in accordance with the Labour law of the State of Qatar.

### Article ( 9 )

1- The conditions and terms of the employment of Cambodian workers in the State of Qatar shall be defined by an individual work contract concluded between the worker and the employer in accordance with the Model Contract attached to this Agreement. The contract shall contain the basic conditions of work relating to duties and rights that are consistent with the provisions of this Agreement and the Qatari Labour Law.

**2-** The contract shall be issued in Arabic and English in three original copies, one of which is to be kept by the employer, the second by the worker, and the third is to be deposited with the Ministry of Labour in the State of Qatar.

**Article ( 10 )**

The individual employment contract shall include the details of the employer's obligations concerning the worker's accommodation and its type, or the payment of an accommodation allowance, and his medical treatment.

**Article ( 11 )**

The Arabic text of the employment contract is the one recognized by the Ministry of Labour and the courts in the State of Qatar. The employer may not introduce any changes in the provisions of the employment contract unless that shall be more beneficial to the worker and upon the approval to the Ministry of Labour.

**Article ( 12 )**

The employment contracts shall be ratified by the Ministry of Labour in the State of Qatar and the ***Royal*** Embassy of Cambodia in Doha in case the contracts are concluded in the State of Qatar. Contracts concluded in Cambodia are ratified by the Ministry of ***Labour and Vocational Training*** and the Embassy or Consulate of the State of Qatar in the Kingdom of Cambodia.

**Article ( 13 )**

1-The competent authority at the Ministry of Labour in the State of Qatar shall monitor the implementation of the provisions of this Agreement.
2-In case of a dispute between the employer and the worker arising from the employment contract, the complaint shall be lodged with the Ministry of Labour for amicable settlement. If an amicable settlement is not reached, the dispute shall be referred to the competent judicial authorities in the State of Qatar.

**Article ( 14 )**

The employment contract shall terminate on the date set for its expiration without a prior notice. If the employer wishes contract to continue, he shall

inform the worker in writing of his wish to renew the contract at least thirty days before the expiry of the contract.

### Article ( 15 )

The worker is permitted to transfer to Cambodia savings from his wages in accordance with the financial regulations followed in the State of Qatar.

### Article ( 16 )

The two sides shall establish a joint committee composed of not more than five members from each side to perform the following functions:

1- To coordinate between the two Governments to implement this Agreement and take the necessary measures in this regard.
2- To interpret the provisions of this Agreement in case of a dispute related to it and settle any difficulties arising in its implementation.
3- To review job opportunities available in the State of Qatar, including general information on development plans in the State of Qatar, the potential work opportunities under these plans, the types and classes of labour and needed skills, and the willingness of the citizens of Cambodia to make use of them.
4- To propose review or modification of all or some of the provisions of this Agreement if necessary.

The committee shall alternately meet once a year in the two countries. It shall also meet when the need arises.

### Article ( 17 )

The amendment of this Agreement shall be made by agreement of the two Governments and after following the same legal procedures required for the conclusion of this Agreement.

### Article ( 18 )

This agreement shall be subject to ratification by the two Contracting Parties and shall enter into force from the date of the exchange of its instruments of

ratification. It shall remain in force for three years, renewable for a similar period, unless either Contracting Party requests its termination by a written notice six months before its expiry.

In witness thereof, we the undersigned below, have signed this Agreement.

Done in Doha On 6/6/1432 A.H. corresponding to 9/5/2011, issued in Arabic, Khmer, and English all texts are equally authentic, and in case of any difference the English text shall prevail.

| For the State of Qatar | For the Kingdom of Cambodia |
|---|---|
| **Nasser Bin Abdullah AL Hamidi** | **VONG SAUTH** |

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលុបឈ្មោះមន្ត្រីរាជការចំនួន ០១ រូប ក្នុងឋានន្តរសក្តិឧត្តមមន្ត្រីការបរទេស នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមូលហេតុមរណភាព ៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង | ឋានន្តរសក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំលុបឈ្មោះ |
|---|---|---|---|---|---|---|
| ១ | **លង់ គឹមឃួន** | ប | ២៥-០៥-១៩៥៥ | អតីតប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា | ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៥ | ០១-១១-២០១១ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៥.១២០៩.៧២២

លេខ:៧៤៨ ច.ល
បានយកសេចក្តីក្រាបបង្គំទូល
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១២
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ៈ** ដំឡើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ដល់ នាយទាហាន នៃកងយោធពលខេមរភូមិន្ទៈ

១-ឧត្តមសេនីយ៍ទោ **ម៉ៅ សុវណ្ណ** អត្តលេខ ០០០២៧៥

២-ឧត្តមសេនីយ៍ទោ **ជា កែវ** អត្តលេខ ០០៤៣៥១

**មាត្រា២ៈ** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ៈ** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤. ១២០៩. ៩២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

លេខៈ៧៤៣ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានលុបឈ្មោះ ឧត្តមសេនីយ៍ទោ ច័ន្ទ រិទ្ធី អត្តលេខ ០១០២១១ ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៧៨៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
...សុខា

ចាស. ១៧០៩. ៤៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានលុបឈ្មោះ នាយទាហាន ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ៖

១-ឧត្តមសេនីយ៍ទោ ខឹម ង៉ិន អត្តលេខ ០០៨៣៥៥

២-ឧត្តមសេនីយ៍ទោ ឃួន វឿន អត្តលេខ ០០០១៥០

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ភាគ. ១២០៩. ៩២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

លេខ: ៧៨៥០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី ពេជ្រ សុធិរា អត្តលេខ ០៥៣៧២ នាយនគរបាលជាតិជាន់ខ្ពស់ ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៧៩៦ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
សយ សុខា

ពរស.១២០៩.៩២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩២០

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស / រកត / ០២០០ / ១០៤ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់ឯកឧត្តម **ជា សុផារ៉ា** ឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ តទៅ ដោយរក្សាមុខតំណែងនយោបាយនៅដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣នក ១២០៩.៩២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

[illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៤២១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **ទឹម ទុំ** អត្តលេខ ១២១៨២
២- លោកវរសេនីយ៍ឯក **ម៉ែន ចណ្ណា** អត្តលេខ ០១០៧៨
៣- លោកវរសេនីយ៍ឯក **ព្រុំ សន្ធរ** អត្តលេខ ៦៨២៣៩
៤- លោកវរសេនីយ៍ឯក **ឡុង ស្រេង** អត្តលេខ ០៥៩៥៩
៥- លោកវរសេនីយ៍ឯក **តំក្រ ចាន់ឌី** អត្តលេខ ២០៤០៣
៦- លោកវរសេនីយ៍ឯក **អៃ សារឹម** អត្តលេខ ០៧៥៤
៧- លោកវរសេនីយ៍ឯក **អេលឹត កុសលបុត្រ** អត្តលេខ ៦៥៩៩៩
៨- លោកវរសេនីយ៍ឯក **ទឹន ប្រសើរ** អត្តលេខ ០៣៦២៤
៩- លោកវរសេនីយ៍ឯក **ឃឹម យោល** អត្តលេខ ០៣៦០០
១០- លោកវរសេនីយ៍ឯក **អ៊ូ ចាន់កុសល** អត្តលេខ ០៥០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

១១- លោកវរសេនីយ៍ឯក **សឿន ផល្លា** អត្តលេខ ០៤៤៤៤

១២- លោកវរសេនីយ៍ឯក **អ៊ិត សិទ្ធិ** អត្តលេខ ០៦៧៩

១៣- លោកវរសេនីយ៍ឯក **សរ ម៉ាន់ថុន** អត្តលេខ ០២៩៥៩

១៤- លោកវរសេនីយ៍ឯក **ចាន់ សុផល** អត្តលេខ ០៣០៥

១៥- លោកវរសេនីយ៍ឯក **អ៊ឹម ចិសាន** អត្តលេខ ០១០៣១

១៦- លោកវរសេនីយ៍ឯក **ហេង សុគ្គា** អត្តលេខ ០១០៣៦

១៧- លោកវរសេនីយ៍ឯក **ខៀវ ស៊ីណាត** អត្តលេខ ០២២៨២

១៨- លោកវរសេនីយ៍ឯក **អ៊ុំ ម៉ូនី** អត្តលេខ ០២១៦៧

១៩- លោកវរសេនីយ៍ឯក **សុខ មិន** អត្តលេខ ០៥២៧១ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស/រកត. ០៩១២. ៨២៤*

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២*

លេខ: ៧៤០ ច.ល
ថតចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី ជ.រដ្ឋលេខាធិការ

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៧២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **យឹម សំណាង** អត្តលេខ ០៣៧៩ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរព.១២០៩.៥២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

លេខៈ ៧៩៥ ០ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៤៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សមាជិកក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិ នៃលេខាធិការដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ចំនួន១០រូប
ដែលបានខិតខំពុះពារគ្រប់ការលំបាកក្នុងការអភិវឌ្ឍវិស័យអគ្គិសនីជនបទនៃព្រះរាជាណាចក្រកម្ពុជា
រួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិសម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

ឯកឧត្តម សួន ម៉េងគា

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១-ឯកឧត្តម ស៊ឹម សុន ៣-លោក សរ គីនីវ៉ា
២-ឯកឧត្តម ថេង បញ្ញាធន

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

លោក គង់ ពុទ្ធី

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-លោក ជាប សត្ថារតន៍ ៤-លោក ស៊ុម តារា
២-លោក អ៊ែនឌី ភាំង ៥-លោក ឈឿង កែវសិលា
៣-លោក ស៊ាង ហាក់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៧៧៩ច.ល

...ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២
...លេខាធិការ...រាជរដ្ឋាភិបាល
...សុខា

៧៨០.១២០៩.៤៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហោរាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជននិងមន្ត្រីរាជការចំនួន ១៤រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយអភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ និងជួយផ្នែកមនុស្សធម៌ នៅក្នុងខេត្តព្រះសីហនុ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់ **ធិបឌិន្ទ** :

១-លោកវរសេនីយ៍ត្រី **ឃឹម ចាន់ថុល** | ២-លោកអនុសេនីយ៍ទោ **តាន់ ពៅពិណោ**
៣-លោកអនុសេនីយ៍ទោ **ហេង សុវណ្ណ** | ៤-លោកអនុសេនីយ៍ទោ **ម៉ៅ សុខា**
៥-លោក **ចុល ចេក** | ៦-លោក **ចឹង សុវិទ្យា**
៧-លោក **ប៉ាង សារ៉ាដែន** | ៨-លោក **សម ឆួន**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់ **សេនា** :

១-លោកវរសេនីយ៍ត្រី **ទូច ជាណារ៉ា** | ២- លោកវរសេនីយ៍ត្រី **ថោង ចន្ថា**
៣- លោកអនុសេនីយ៍ឯក **មាស ហាត** | ៤- លោកអនុសេនីយ៍ទោ **ពេជ្រ សារិទ្ធ**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា**ថ្នាក់ **អស្សឫទ្ធិ** :

១-លោកវរសេនីយ៍ត្រី **ហោ សំអាត** | ២- លោកវរសេនីយ៍ត្រី **ចាន់ សំណាង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៦. ១២០៩. ៩៣១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១២

លេខៈ ៧៨៧ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន ចំនួន ៤៧ រូប នៃកងយោធពលខេមរភូមិន្ទ
និងអង្គភាពសប្បុរសជនស៊ីវិល ចំនួន ០២ មានស្នាដៃល្អក្នុងការបម្រើជាតិមាតុភូមិ

នូវ

**ក-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :**

-ឧត្តមសេនីយ៍ត្រី **សុទ្ធ សុិនសំបូរ** អត្តលេខ ០០៩៤៨២

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឧត្តមសេនីយ៍ទោ **ហៃ សារ៉ន** អត្តលេខ ០០១៩៥៧
២-ឧត្តមសេនីយ៍ត្រី **រស់ គង់** អត្តលេខ ០០៨៨០២
៣-វរសេនីយ៍ឯក **ហាស់ ពពូល** អត្តលេខ ០០១៩៥០
៤-វរសេនីយ៍ឯក **ខឿ សុជាតិ** អត្តលេខ ០១៧៩៥០

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-អង្គភាព រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២-ក្រុមហ៊ុនថាវី ពាណិជ្ជ នីហរ៍ណ អាហរ៍ណ

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-វរសេនីយ៍ឯក **សុខ ដែន** អត្តលេខ ០២១៧៥៨
២-វរសេនីយ៍ឯក **បែល ម៉ិនផល** អត្តលេខ ០១៦៦៧០
៣-វរសេនីយ៍ទោ **ហ៊ីម សុទ្ធារិទ្ធ** អត្តលេខ ០៣៧៥៧១
៤-វរសេនីយ៍ទោ **ថៃ អ៊ិតណាយ** អត្តលេខ ០០៤៩០៨
៥-វរសេនីយ៍ទោ **សេស យ៉ុង** អត្តលេខ ០១១៣៤៦
៦-វរសេនីយ៍ទោ **អ៊ុយ សុភីណា** អត្តលេខ ០២៥៩១៤

៧-វរសេនីយ៍ទោ ម៉ក ចន្ទវីរៈ អត្តលេខ ០១៦៦២៩

## ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-វរសេនីយ៍ឯក ព្រុំ សុខន អត្តលេខ ០០២៤៥២
២-វរសេនីយ៍ឯក អ៊ុំ ឈុំ អត្តលេខ ០០៩២០៥
៣-វរសេនីយ៍ឯក ព្រហ្ម វណ្ណាដា អត្តលេខ ០០២៤៥៧
៤-វរសេនីយ៍ឯក ស៊ុម សេង អត្តលេខ ០០២៤៥៤
៥-វរសេនីយ៍ឯក អ៊ុក ចាន់ឡឿន អត្តលេខ ០០៩២០៣
៦-វរសេនីយ៍ឯក ទេព ដួប អត្តលេខ ០០៩១៩៩
៧-វរសេនីយ៍ទោ ម៉ៅ គឹមនី អត្តលេខ ០០៩២០៧
៨-វរសេនីយ៍ទោ សៅ ស៊ុន អត្តលេខ ០០៩១៩៨
៩-វរសេនីយ៍ទោ ហែម ញូង អត្តលេខ ០២១៧៩៧
១០-វរសេនីយ៍ទោ អ៊ុង ស៊ីវុឌ្ឍី អត្តលេខ ០០៩២០៤
១១-វរសេនីយ៍ទោ យី វណ្ណារដ្ឋ អត្តលេខ ០០៩២០១
១២-វរសេនីយ៍ទោ អ៊ុក វណ្ណារិទ្ធ អត្តលេខ ០១៨៣៣២
១៣-វរសេនីយ៍ទោ ឡឿន វុទ្ធី អត្តលេខ ០១៨២០៧
១៤-វរសេនីយ៍ទោ ឃឹម សុគន្ធធឿន អត្តលេខ ០១៨៣២៧
១៥-វរសេនីយ៍ទោ អ៊ាន ចិន្តា អត្តលេខ ០៣៤០៦៨
១៦-វរសេនីយ៍ត្រី ឡុង ពិសិដ្ឋ អត្តលេខ ០១៨៣១៥
១៧-វរសេនីយ៍ត្រី សយ សុវណ្ណា អត្តលេខ ០៤៧៩៤១
១៨-វរសេនីយ៍ត្រី ម៉ៅ សុខុម អត្តលេខ ០០៩២៤៧

## ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-វរសេនីយ៍ត្រី ម៉ិច ចាន់ អត្តលេខ ០១៨៣១៨
២-វរសេនីយ៍ត្រី កៅ អៀង អត្តលេខ ០២៧៣៦៤
៣-វរសេនីយ៍ត្រី ឡុង សុទ្ធី អត្តលេខ ០៤០៦០៦
៤-វរសេនីយ៍ត្រី អ៊ុំ សៃយ៉ា អត្តលេខ ០២៧៥០០
៥-វរសេនីយ៍ត្រី ឯម ចំរើន អត្តលេខ ០១៨៣២៩
៦-វរសេនីយ៍ត្រី សេង សង អត្តលេខ ០៩០៦៦៩
៧-វរសេនីយ៍ត្រី អូន លីហ៊ីន អត្តលេខ ០១៧២៨៧
៨-វរសេនីយ៍ត្រី គូ ផល្លា អត្តលេខ ០៨៩៦៧៩
៩-វរសេនីយ៍ត្រី វង្ស សុភ័ក្រ អត្តលេខ ០២៧៤៩២
១០-វរសេនីយ៍ត្រី ឈុន ចាន់បុត្រ អត្តលេខ ០១៩៣៤០
១១-វរសេនីយ៍ត្រី អ៊ឹម ចាន់ថុល អត្តលេខ ០២៧៤៨៣



១២-វរសេនីយ៍ត្រី **ហួត ហ៊ិន** អត្តលេខ ១៩៦៧៨៣

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-វរសេនីយ៍ទោ **វ៉ាត់ សួយ** អត្តលេខ ០១៧៥១៦

២-វរសេនីយ៍ត្រី **ម៉ៅ ឌុទ្ធី** អត្តលេខ ១៥៦៥៩២

៣-វរសេនីយ៍ត្រី **តាំង រុន** អត្តលេខ ០៣៥១២៦

៤-វរសេនីយ៍ត្រី **មិុច ម៉ិនធឿន** អត្តលេខ ០៦៨១៤៩

៥-វរសេនីយ៍ត្រី **ញាណ សុភា** អត្តលេខ ០៦៥៩៥៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចាស.១២០៩.៥៣២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២*

លេខៈ ៧៩១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្ដីការរដ្ឋាភិបាល**

សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៨៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងព្រះគ្រូ **នៅ ឃី** ប្រធានពុទ្ធមណ្ឌលវិបស្សនាធុរៈកម្ពុជា ឱ្យឡើងទីជា **ព្រះធម្មវិបស្សនា** ព្រះរាជាគណៈថ្នាក់ចត្វា គណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៧៨៤០.ល
**សម្រាប់ចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរង[illegible]រដ្ឋាភិបាល**
[illegible] សុខា

៣៣៧.១៤០៩.៨៣៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២*

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៥២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សពឯកឧត្តម ចាន់ តិន

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

ន សីហមុនី

៣១៣.១២០៩.៥៣៥

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៣០/១២....រ.ចប
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា.... ឆ្នាំ ២០១២
សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១០/៦៤៥ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១០ ស្តីពីលក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ចំពោះ ឧត្តមសេនីយ៍ត្រី ណូវ ចំណាន អត្តលេខ ០៤២៩៣៧ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាហ.១២០៩.៧៣៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

លេខ: ៨០០ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
[signature]
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លាង ខេនស៊ុង** (LEONG KHEN TSHUNG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៨១ នៅខេត្តសាបា ប្រទេសម៉ាឡេស៊ី ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៧៧ ៦ច.ល
**...ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរង...រាជរដ្ឋាភិបាល**
**... សុខា**

ចាស. ១២០៩.៩៣៩

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៣២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ៊ូ អែនតូនី តេងជុន** (HU ANTHONY, TENGJUN) ជនជាតិចិន សញ្ជាតិបារាំង កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨៣ នៅខេត្តស៊ីជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ហ៊ូ អែនតូនី** ( HU ANTHONY) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៧៧៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សុខា

៣៩៧.១២០៩.៩៣៩

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **អ៊ុំមី កុលស៊ុំ ម៉ែនណាន** (UMME KULSUM MANNAN) ជនជាតិបង់ក្លាដែស សញ្ជាតិបង់ក្លាដែស កើតថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៦៥ នៅទីក្រុងជីតាហ្កុង ប្រទេសបង់ក្លាដែស។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

មាកស.១២០៩.៥៤០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២*

លេខៈ៧៧៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៥៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ដំឡើងឋានន្តរស័ក្តិជូន ឯកឧត្តម **ជា ចាន់ទុំ** ពីឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងផែនការ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាប្រ. ១២០៩. ៥៤១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២*

លេខ: ៧៥៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១៖** តែងតាំងសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **នន្ទ ងិន** សម្តេចព្រះមហាសង្ឃរាជ នៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជាជា **កិត្តិឧត្តមសេនបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២៖** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣៖** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

ហរលា.១២០៩.៩៤២

លេខៈ ៩០៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកៈនិកាយនៃព្រះរាជាណាចក្រកម្ពុជា ជា**កិត្តិឧត្តមបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៨០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**
សុខា

៣៩៨.១២០៩.៤៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការ កែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជ ក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ៈ** តែងតាំងសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយកនៃ ព្រះរាជាណាចក្រកម្ពុជាព្រះអគ្គាធិការពុទ្ធិកសិក្សាជាតិ ជា **កិត្តិឧត្តមបណ្ឌិត** នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា២ៈ** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ៈ** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៧០៣ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
[illegible] សុខា

៣៦៦.១២០៩.៤៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៣ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ចេញពីផែនទីគម្របព្រៃឈើអចិន្ត្រៃយ៍ឆ្នាំ ២០០២**
**នូវផ្ទៃដីសរុបទំហំ ១.៧២១ ហិកតា នៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង**
**និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ និងការធ្វើប្រទានកម្មជាកម្មសិទ្ធិ**
**ជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១០៧២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- តាមសំណើលេខ ១២២៦ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីចេញពីគម្របព្រៃឈើ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវចំណែកផ្ទៃដីទំហំ ១.៧២១ (មួយពាន់ប្រាំពីររយម្ភៃមួយ) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងភូមិគោករកា ឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលមានប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។ ក្នុងទំហំដីទាំងនេះ មាន៖

- ចំណែកផ្ទៃដីទំហំ ១៦៣ (មួយរយហុកសិបបី) ហិកតា ត្រូវកាត់ចេញពី គម្រោងព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ តាមលិខិតលេខ ២២០ សជណ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងកិច្ចព្រមព្រៀងវិនិយោគព្រៃសម្បទាន ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៨ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន យូរីសាគរ ។
- ចំណែកផ្ទៃដីទំហំ ១,៥៥៨ (មួយពាន់ប្រាំរយហាសិបប្រាំបី) ហិកតា ស្ថិតក្នុងដែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ ២០០២ ដែលមានដីកាដកហូតលេខ ៨៩ ដក.អនគ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៦ និងដីកាលេខ ១៨៤ ដក.អនគ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៦ របស់ខេត្តបាត់ដំបង។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៩១១ (ប្រាំបួនរយដប់មួយ) គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង លើក្បាលដីចំនួន ៩៣៥ ក្បាលដី។

**មាត្រា ៣ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុកសម្រាប់ផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៥៤ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២១១/ ០១៩ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញប្រកាសលេខ ១១០៧ សហវ ថ.ប្រក,ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## **<u>សម្រេច</u>**

**<u>មាត្រា១</u>**: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ១៧១.០០០.០០០ រៀល (មួយរយចិតសិបមួយលានរៀលគត់ ) ពីជំពូក ៦០ (ការទិញ)មកជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងផែនការ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ។

**<u>មាត្រា២</u>**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការចំណាយទទួលគណៈប្រតិភូផែនការវិនិយោគវៀតណាម និងចំណាយរៀបចំកិច្ចប្រជុំអគ្គនាយកស្ថិតិអាស៊ាននៅខេត្តសៀមរាប ។

**<u>មាត្រា៣</u>**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១៣

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨០៥/៣៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត ០៤១១/៣៤០ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមុខតំណែងសមាសភាពថ្នាក់ដឹកនាំមួយចំនួន នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ២៥ អនក្រ/បក ចុះថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១០ ស្តីពីការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

## ស ម្រ េ ច

**មាត្រា ១.-**

អនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារឆ្នាំ ២០១៣ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៥ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ | សម្រាក០៣ ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៤ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៨ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៣-០៤-០៥ | តុលា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ៣១ | តុលា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា **ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១៦-១៧-១៨ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានឱ្យឈប់ចំនួន០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតឱ្យឈប់សម្រាកបន្ថែមជាជំនួស គឺឈប់ចំនួន ០១ ថ្ងៃតែប៉ុណ្ណោះ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព

### ក-ដំឡើងឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក

១- វរសេនីយ៍ទោ **មាស សុវណ្ណា** អត្តលេខ ០០៨៥៥០ នាយករងសាលាថែទាំវេជ្ជសាស្ត្រ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ

២- វរសេនីយ៍ទោ **ញឹម សារឿន** អត្តលេខ ០៩៧០៧១ នាយផ្នែកបកស្រាយដោយរូបថត ការថតរូប ការិយាល័យបោះថត នាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ

៣- វរសេនីយ៍ទោ **ម៉ៅ សាខុន** អត្តលេខ ០១៨២៥៩ នាយរងការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងអាកាស អគ្គបញ្ជាការដ្ឋាន

៨- វរសេនីយ៍ទោ **សេន មឿន** អត្តលេខ ០០៩២៨៨ នាយសេនាធិការរង កងពលតូច អនុភាគមន៍លេខ១ អគ្គបញ្ជាការដ្ឋាន

**ខ. ដំឡើងឋានន្តរស័ក្តិថ្នាក់វរនាវីឯក**

- វរនាវីទោ **អ៊ឹម ខួន** អត្តលេខ ០១០២៧៣ នាយរងការិយាល័យគោលនយោបាយ ស្នងការដ្ឋានឃោសនាពត៌មាន បញ្ជាការដ្ឋានកងទ័ពជើងទឹក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប នៃក្រសួងផែនការ ដូចមានរាយនាមខាងក្រោម ÷

១. លោក **អ៊ុខ យ៉ាន** អនុមន្ត្រី ថ្នាក់លេខ ១១ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃ អគ្គនាយកដ្ឋានផែនការ ជំនួសឯកឧត្តម **ឆៃ ម្នូរ** ដែលត្រូវចូលនិវត្តន៍

២. លោក **ម៉ុន ថា** នាយក្រមការ ថ្នាក់លេខ ៤ ឱ្យបំពេញមុខងារជាអធិការ នៃ អគ្គាធិការដ្ឋាន ជំនួសលោក **អ៊ុខ យ៉ាន** ដែលទទួលភារកិច្ចថ្មី។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២០៣ អនក្រ.តក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ចំនួន ០២ រូប :

១- លោក **ក្រៃ ស៊ុនហៀង** ជា **អគ្គាធិការរង** ជំនួសលោក ង៉ែត សូភិន ដែលត្រូវទទួលភារកិច្ចថ្មី

២-លោក **លឿង រដ្ឋា** ជាប្រធាននាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ ជំនួសលោក ឈឹម ខាន់ ដែលចូលនិវត្តន៍ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខា ធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកម/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងទៅក្នុងឋានន្តរស័ក្តិ វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ស្របទៅតាមមុខតំណែង ជូនមន្ត្រីរាជការស៊ីវិល ៖

| ល.រ | គោត្តនាម និងនាម | ភេទ | ឋានន្តរស័ក្តិ ថ្នាក់ចាស់ | ឋានន្តរស័ក្តិ ថ្នាក់ថ្មី |
|---|---|---|---|---|
| ១ | **មឿង ស៊ាងសេង** | ស្រី | ពី អនុមន្ត្រី ថ្នាក់លេខ ១១ | ទៅជា វរមន្ត្រី ថ្នាក់លេខ ១០ |
| ២ | **ជុន ចាន់ឿត** | ប្រុស | ពី អនុមន្ត្រី ថ្នាក់លេខ ១១ | ទៅជា វរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៤៩០ ឧរថ.គក.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២

## ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ១៤៨០ /១២ គ.វ.ក ចុះថ្ងៃទី០៤.០៧.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឌ្រីម ថយ អ៊ិនធើណេសិនណល ចុះថ្ងៃទី១៥.០៦.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឌ្រីម ថយ អ៊ិនធើណេសិនណល (DREAM TOYS INTERNATIONAL CO.,LTD.) តំណាងដោយ លោក AHN YONG BAE សញ្ជាតិកូរ៉េ អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខM59045783 ចុះថ្ងៃទី០៣.០៤.២០១[illegible] ស្នាក់នៅអាសយដ្ឋានបច្ចុប្បន្ន ៖ Seoul Kwang Jin Gu Achasanro 537-17, 1402 Dong 1404HO(Kwang Jang Dong, Kwang Jang Hill State). ជាម្ចាស់រោងចក្រ [illegible] ធ្វើការបង្កើតរោងចក្រលើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| តុក្កតាគ្រប់ប្រភេទ | ៣២៤០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតតុក្កតាគ្រប់ប្រភេទ ឡើម ថយ អ៊ិនធើណេសិនណល"*

**ទីតាំងរោងចក្រ៖** *"ភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

